**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់មន្ត្រីរាជការឱ្យនៅក្រៅក្របខ័ណ្ឌដើមក្នុងពេល បំពេញការងាររៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០៤២ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់
- តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## សម្រេច

**មាត្រា ១.–**

មន្ត្រីរាជការដែលត្រូវបានតែងតាំងជាប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យសុំទៅបំរើការងារក្រៅក្របខ័ណ្ឌដើមរហូតដល់មានការតែងតាំងថ្មី ។ ក្នុងរយៈពេលនេះសាមីខ្លួនត្រូវបានរក្សាអតីតភាពការងារសំរាប់ការឡើងថ្នាក់ និង ទទួលសោធននិវត្តន៍ ប៉ុន្តែមិនទទួលបៀវត្សទេ ។

**មាត្រា ២.–**

មន្ត្រីរាជការដែលត្រូវបានជ្រើសរើសជាប្រធាន អនុប្រធាន សមាជិកនៃគណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោត មន្ត្រីបំរើឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងមន្ត្រីបំរើឱ្យ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យសុំទៅបំរើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ចប់ភារកិច្ច ។ ក្នុងរយៈពេលនេះ សាមីខ្លួនត្រូវបានរក្សាអតីតភាពការងារសំរាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍ ប៉ុន្តែមិនទទួលបៀវត្សទេ ។

**មាត្រា ៣.–**

មន្ត្រីរាជការដែលត្រូវបានជ្រើសរើសជាប្រធាន អនុប្រធាន សមាជិកគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យសុំឈប់ពិសេសទៅបំរើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការ ។ ក្នុងការឈប់ពិសេសនេះ សាមីខ្លួនត្រូវបានរក្សាបៀវត្ស អតីតភាពការងារសំរាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍ ។

**មាត្រា ៤.–**

មន្ត្រីរាជការ ដែលត្រូវបានជ្រើសរើសជាសមាសភាពការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ត្រូវដាក់ពាក្យសុំឈប់ពិសេសទៅបំរើការងារក្រៅក្របខ័ណ្ឌដើម រហូតដល់ចប់ភារកិច្ច ។ ក្នុងការឈប់ពិសេសនេះ មន្ត្រីរាជការត្រូវបានរក្សាបៀវត្ស អតីតភាពការងារសំរាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍ ។

**មាត្រា ៥.–**

គ្រប់ក្រសួង ស្ថាប័ន មន្ទីរ ឬអង្គភាពរដ្ឋ ត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរាជការដែល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានជ្រើសរើស និងតែងតាំងឱ្យចូលរួមក្នុងការងារបោះឆ្នោត បានឈប់ពីការងារតាមសំណូមពរ និង បានចូលបំរើការងារនៅអង្គភាពដើមវិញក្រោយពេលចប់ភារកិច្ច ។

មន្ត្រីរាជការដែលទទួលបានការជ្រើសរើស និងតែងតាំងដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវដាក់ពាក្យសុំចូលបំរើការងារវិញតាមឋានានុក្រមនៃក្រសួង ស្ថាប័នសាមី ។

លិខិតអនុញ្ញាតអោយឈប់ពិសេស និងលិខិតអនុញ្ញាតឱ្យចូលបំរើការងារវិញរបស់ក្រសួង ស្ថាប័ន មន្ទីរ ឬអង្គភាពរដ្ឋ ត្រូវចម្លងជូនទីស្តីការគណៈរដ្ឋមន្ត្រី និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៦.-**

មន្ត្រីរាជការ ដែលត្រូវបានចាត់តាំងអោយបន្តនិរន្តរភាពការងារបោះឆ្នោត នៅគណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោត ត្រូវសុំបន្តការងារនៅក្រៅក្របខ័ណ្ឌដើមចាប់ពី មានសេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតែងតាំង អោយបន្តការងាររហូតដល់ចប់ភារកិច្ច ។ ក្នុងរយៈពេលនេះ សាមីខ្លួនត្រូវបានរក្សាអតីតភាពការងារសំរាប់ឡើងថ្នាក់ និងទទួលសោធននិវត្តន៍ ប៉ុន្តែមិនទទួលបៀវត្សទេ ។

**មាត្រា ៧.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងមន្ត្រីរាជការ ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី**

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**ឆេង ផុន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
- *គ្រប់ក្រសួង ស្ថាប័ន*
- *ឯកសារ_កាលប្បវត្តិ*